# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៦/០០៩ /២០០៤
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៥/០០៧/២០០៤ កបធ.ច
ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២៥៣ រស ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតនេះ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ៧:៤៨ ព្រឹក ។

-បានឃើញសេចក្តីសម្រេចលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា " ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ " ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទបញ្ញត្តិទាំងឡាយណាដែលបានចែងថា " ... ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី ៣ " ដែលជាទោសសម្លាប់ ក្នុងមាត្រា ២០៩ មាត្រា ៥០០ មាត្រា ៥០៦ និង មាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ ។

-បានឃើញសេចក្តីសម្រេចលេខ ០៤៣/០០៥/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែល

រដ្ឋសភាបានអនុម័តយល់ព្រមផ្ទៃនីយតកម្ម កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ស្របនឹងរដ្ឋធម្មនុញ្ញ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះដោយប្រធានរដ្ឋសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លា ទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ចំណុចដែលបានកែប្រែមានជាអាទិ៍ដូចតទៅ ÷

១-ការកែប្រែអាជ្ញាយុកាល ( មាត្រា ៣ ថ្មី ) គឺអាជ្ញាយុកាលនៃពាក្យបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំ តទៅទៀត ( រីឯមាត្រា ៣ ចាស់ អាជ្ញាយុកាលនេះ ត្រូវបានពន្យារពេលបន្ថែម ២០ ឆ្នាំ ទៀតតែប៉ុណ្ណោះ ) ។

២-ការកែសម្រួលរចនាសម្ព័ន្ធសាលាជម្រះក្តី ( មាត្រា ៣ ថ្មី ) គឺរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញដែលមាន ៣ ថ្នាក់ ត្រូវបានសម្រួលមកត្រឹម ២ ថ្នាក់ គឺសាលាដំបូង និង តុលាការកំពូល ( តុលាការកំពូលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងសម្រេចសេចក្តីចុងក្រោយផង ) ។

៣-ការកែប្រែសមាសភាពនៃអង្គជំនុំជម្រះតុលាការកំពូលឱ្យមានចៅក្រមខ្មែរ ៤ រូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមអន្តរជាតិ ៣ រូប ។ អង្គជំនុំជម្រះតុលាការកំពូលនេះ សម្រេចសេចក្តីបិទផ្លូវតវ៉ា (មាត្រា ៩ ថ្មី) ។

៤-ការកែប្រែអំពីសិទ្ធិពេញលេញរបស់ជនជាប់ចោទ និង អភ័យឯកសិទ្ធិសម្រាប់មន្ត្រីតុលាការ និង មេធាវី ដោយផ្អែកលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ ( មាត្រា ៤២ ថ្មី ) ។

៥-ការកែប្រែបន្ថែមអំពីនីតិវិធីឱ្យបានច្បាស់ថែមទៀតដូចតទៅនេះ : " ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងអំពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពមិនសមស្របនៃនីតិវិធីទាំងអស់នេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ " (មាត្រា ២០ ថ្មី មាត្រា២៣ ថ្មី ) ។

៦-ការចែងបន្ថែមអំពីវិសាលភាពនៃការលើកលែងទោស និង អនុគ្រោះទោសដែលអាចផ្តល់ឱ្យមានមុនការអនុម័តច្បាប់នេះ គឺសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ( មាត្រា ៤០ ថ្មី ) ។

៧-ការចែងបន្ថែមអំពីល័ក្ខខ័ណ្ឌចៅក្រមដែលត្រូវតែងតាំង ហើយបំរើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវមានបទពិសោធន៍រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង ( មាត្រា ១០ ថ្មី ) ។

៨-សហព្រះរាជអាជ្ញាបរទេស មានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារងបរទេស ( មាត្រា ២២ ថ្មី ) ។

៩-ការចែងបន្ថែមអំពីភាពមិនអាចរំលោភបំពានបាននៃបណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និង ជាទូទៅឯកសារ និង

សម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬ ប្រើប្រាស់ដោយជនណាក៏ដោយ ក្នុងរយៈពេលនៃដំណើរការជំនុំជម្រះនេះ ( មាត្រា ៤២ ថ្មី )។

១០-ការកាត់បន្ថយការប្រើប្រាស់ភាសាជាផ្លូវការមកត្រឹម ៣ ភាសា គឺភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង ( មាត្រា ៤៥ ថ្មី )។

១១-ការកែប្រែដោយលុបចោលបទបញ្ញត្តិដូចតទៅ :

-លុបពាក្យ " មូលនិធិស្ម័គ្រចិត្ត " នៅក្នុងចំណុចទី ២ នៃមាត្រា ៤៤ ចាស់

-លុបចំណុចទី ៣ នៃមាត្រា ៤៤ ចាស់ ។

ចំណុចកែប្រែទាំង ១១ ខាងលើ និងចំណុចកែប្រែដទៃទៀត ពុំមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនេះ ពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ~ ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** ~ សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**